**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Club of Cambodian Journalists

លេខ...33/២៥...ក.អ.ក

ក្លិបអ្នកកាសែតកម្ពុជា
ប្រធាន
លោក ពុយ គា
អគ្គលេខាធិការ
លោកស្រី ថុង សុវណ្ណរង្សី
គណៈកម្មាធិការនាយក
លោក ខៀវ កូឡា
លោក ជេត សន
លោក ទាវ សារៈមុនី
លោក នៅ សុភ័ស្ស
កញ្ញា យ៉ាន់ លីណា
លោក លាង ដីលុច
លោក សៅ ភិរុណ
សមាជិកស្ថាបនិក
លោក ប៉ែន សមិទ្ធិ
លោក ឆាយ សុផល
លោក ខៀវ កូឡា
លោក ជេត សន
លោក ខាន់ សុឃេន
លោក រាជ សម្បត្តិ
លោក សាំង សុគន្ធរិទ្ធ
លោក ជិន ចាន់មុនី
លោក ប្រាជ្ញ ស៊ីម
លោក ឃួន វិចិត្រ
លោក រស់ ថាន់សន
លោក កែវ សុធា
លោក ឯក សំអាត
លោក ផាន់ សីហា
លោក ឈា វ៉ារី
អ្នកស្រី សុផាត នារីរត្ន័
លោក យូ បូ

# សេចក្តីប្រកាសព័ត៌មាន

ជម្លោះព្រំដែនកម្ពុជា-ថៃ បានធ្លាក់ក្នុងស្ថានភាពកាន់តែធ្ងន់ធ្ងរបន្ទាប់ពីការវាយប្រហារជាថ្មីពីសំណាក់ទាហានថៃចាប់តាំងពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ រហូតមកទល់នឹងថ្ងៃនេះ ហើយក៏ពុំទាន់ដឹងថានឹងបានធូរស្បើយ ឬបទឈប់បាញ់ថ្មីនឹងចូលជាធរមាននៅពេលណាឡើយ។ ការវាយប្រហារដ៏កម្រោល និងអមនុស្សធម៌របស់ទាហានថៃបានសម្លាប់ជនស៊ីវិលកម្ពុជាយ៉ាងហោចណាស់១១នាក់ ក្នុងនោះមានទាំងកុមារ និង៧៤នាក់ផ្សេងទៀតបានរងរបួសរួមទាំងអ្នកសារព័ត៌មានផង។

ជាមួយគ្នានេះ ការវាយប្រហារដ៏ឃោរឃៅរបស់ទាហានថៃបានធ្វើឱ្យពលរដ្ឋកម្ពុជារស់នៅតាមបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសថៃជិត២០ម៉ឺននាក់បានក្លាយជាជនភៀសសឹក សាលារៀនជិត៦០០ខ្នងត្រូវបានបិទទ្វារ និងសិស្សសាលាជាង១៣ម៉ឺននាក់ត្រូវបោះបង់ការសិក្សា។

ដើម្បីផ្តល់ព័ត៌មានពិតអំពីផលប៉ះពាល់ដោយសារអំពើអមនុស្សធម៌ពីសំណាក់ទាហានថៃ ក្លិបអ្នកកាសែតកម្ពុជា (ក.អ.ក) នឹងដឹកនាំអ្នកសារព័ត៌មានជិត៣០រូប មកពី១៣ស្ថាប័នរួមទាំងសារព័ត៌មានផ្សាយជាភាសាបរទេសផង (ភាសាៈ ខ្មែរ អង់គ្លេស បារាំង វៀតណាម និងចិន) ទៅកាន់ជំរំជនភៀសសឹកយ៉ាងហោចណាស់មួយទីតាំងស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ក្នុងគោលបំណងដើម្បីធ្វើបទយកការណ៍ និងធ្វើអត្ថបទនានាស្តីពីទុក្ខលំបាករបស់ជនស៊ីវិលកម្ពុជាដែលរងគ្រោះដោយសារតែការវាយប្រហាររបស់ទាហានថៃមកកាន់តំបន់ព្រំដែន និងលំនៅដ្ឋានរបស់ពួកគាត់។

ក្នុងដំណើរបេសកកម្មរបស់ក្លិបអ្នកកាសែតកម្ពុជា ក៏មានសប្បុរសជនមួយចំនួនបានបរិច្ចាគអំណោយរួមមានៈ តង់ចំនួន៣,០០០ សម្ភារៈប្រើប្រាស់ចាំបាច់ គ្រឿងឧបភោគបរិភោគ រួមទាំងថវិកាផងដើម្បីចែកជូនបងប្អូនជនភៀសសឹកចំនួន១០០០គ្រួសារ។

ក្លិបអ្នកកាសែតកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន ដែលបានចូលរួមជាសម្ភារៈ ថវិកា គ្រឿងឧបភោគបរិភោគសម្រាប់ចែកជូនបងប្អូនជនភៀសសឹកដែលកំពុងជួបការលំបាក។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥
ក្លិបអ្នកកាសែតកម្ពុជា

ផ្ទះលេខ ១២ ផ្លូវលេខ៥ (បុរីប៉េងហួត មុខផ្សារប៉េសេ ផ្លូវ៣៧១) សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
House Nº 12, Street 5 (Borey Peng Huot in front of PC Market), Sangkat Chak Engrae Lue, Khan Mean Chey, Phnom Penh, Kingdom of Cambodia.
Tel: 012 895 853 / 077 480 171 / E-mail : info@ccjcam.com / Website : www.ccjcam.com / Facebook : Club of Cambodian Journalists